# កិច្ចការ ២០:២២-២៥

The following is an abridged translation of a sermon by John Piper.  If you wish to read the original English, go to

http://www.desiringgod.org/sermons/faithfulness-is-better-than-life

សាវកប៉ុលបានចំណាយរយៈពេលបី ឆ្នាំនៅក្នុងក្រុងអេភេសូរ បង្រៀននិងស្ពាងពួកជំនុំ ហើយផ្សាយដំណឹងល្អប្រកបដោយភាពជោគជ័យ រហូតដល់មនុស្សនៅជុំវិញស្រុកអាស៊ីបានស្តាប់លឺព្រះបន្ទូលព្រះ (កិច្ចការ ១៩:១០)។ គាត់បានចាកចេញ  និងបានចំណាយពេលនៅក្នុងក្រុងកូរិនថូសនៅក្នុងរដូវរងា ហើយឥឡូវនេះគាត់កំពុងប្រញាប់ធ្វើដំណើរទៅកាន់ក្រុងយេរូសាឡិម  អោយទាន់ពេលថ្ងៃបុណ្យទី៥០នៅក្នុងឆ្នាំ៥៦គ.ស។ ទូករបស់គាត់ចូលចតនៅមីលេត ចំងាយ៣២គីឡូម៉ែត្រពីខាងត្បូងក្រុងអេភេសូរ ហើយគាត់   អោយគេទៅហៅពួកចាស់ទុំក្នុងពួកជំនុំអោយមក (២០:១៧)។ ហើយនៅក្នុង ២០:១៨-៣៥ គាត់ផ្តាំពាក្យចុងក្រោយដល់ពួកគេ ហើយប្រាប់ថា ពួកគេនឹងមិនឃើញមុខគាត់ទៀតឡើយ។

ដូច្នេះ អ្វីដែលយើងមាននៅទីនេះគឺជាពាក្យសំដីចុងក្រោយរបស់សាវកប៉ុលទៅកាន់ពួកជំនុំមួយ ជាកន្លែងដែលលោកប៉ុលប្រហែលជាបម្រើព្រះគ្រីស្ទយូរជាងគេ។ ពាក្យសំដីនេះគឺជាអ្វី ដែលគាត់ចង់អោយពួកចាស់ទុំលឺជាងគេបង្អស់។ គាត់បានជ្រើសរើសមិននិយាយទៅកាន់ពួកជំនុំទាំងមូលទេ ពីព្រោះគាត់មិនមានពេលគ្រប់គ្រាន់ (២០:១៦) ប៉ុន្តែគាត់មិនអាចធ្វើដំណើរឆ្លងកាត់ដោយមិននិយាយទៅកាន់ពួកចាស់ទុំឡើយ។ នេះបង្ហាញថា លោកប៉ុលគិតថាចាស់ទុំគឺជាមនុស្សសំខាន់ណាស់។ ហើយសេចក្តីពិតដែលថា លោកលូកាផ្អាកនៅក្នុងរឿងរបស់គាត់ ដើម្បីផ្តល់អោយយើងនូវសារនេះបង្ហាញថា សារនេះក៏សំខាន់សំរាប់យើងបានស្តាប់ លឺផងដែរ។

បើសិនអ្នកគឺជាចាស់ទុំម្នាក់ ឬមានបំណងចង់ធ្វើជាចាស់ទុំម្នាក់ ចូរស្តាប់ដោយអស់ពីចិត្ត ហើយដាក់ការទាំងនេះនៅក្នុងជីវិតអ្នក។ បើសិនអ្នកមិនមែនជាចាស់ទុំ នោះចូរធ្វើការពីរ គឺរៀនការទាំងនេះ ដើម្បីអ្នកអាចអធិស្ឋានអោយពួកចាស់ទុំរបស់អ្នកមានការទាំងនេះ ហើយយកការទាំងនេះអនុវត្តមកកាន់ខ្លួនអ្នក ហើយត្រាប់តាមអស់អ្នកណា ដែលចូលមកធ្វើតាមសេចក្តីបង្រៀនរបស់សាវកប៉ុលនៅទីនេះ (ហេព្រើរ ១៣:៧)។

## ការប្តេជ្ញាចិត្តរបស់សាវកប៉ុលគឺជាគំរូមួយ

ពេលមុននេះ យើងបានមើលលើខ.១៨-២១ ប៉ុន្តែថ្ងៃនេះយើងនឹងមើលលើខ.២២-២៥។ ភាពខុសគ្នាមួយរវាងអត្ថបទទាំងពីរគឺថា នៅក្នុងខ.១៨-២១ សាវកប៉ុលបានសំឡឹងមើលត្រឡប់ទៅក្រោយ ហើយនៅ

ក្នុងខ.២២-២៥ គាត់កំពុងសំឡឹងមើលទៅមុខ។ គាត់ចាត់ទុកការប្តេជ្ញាចិត្តគាត់(ទាំងក្នុងអតីតកាលនិងក្នុងពេលអនាគត)ជាគំរូមួយសំរាប់ពួកគេដើរតាម។

ដូចជាគាត់បាននិយាយថា «អ្នកមើលឃើញជីវិតខ្ញុំកាលពីបីបួនឆ្នាំ ដែលយើងបានធ្វើការជាមួយគ្នាហើយ។ ឥឡូវនេះទុកអោយខ្ញុំបង្ហាញអ្នកថា ខ្ញុំយ៉ាងណានៅសព្វថ្ងៃនេះ នៅពេលខ្ញុំប្រឈមនឹងអនាគត ហើយអ្វីដែលសំខាន់សំរាប់ខ្ញុំនៅប៉ុន្មានឆ្នាំខាងមុខ»។

សាវកប៉ុលមិនកំពុងនិយាយឥតចុងឥតដើមអំពីខ្លួនគាត់ដោយឥតមានគោលបំណងឡើយ។ គាត់កំពុងស្អាងចិត្ត ជីវិត និងការប្តេជ្ញារបស់គាត់នៅក្នុងពួកចាស់ទុំ។ ហើយការនេះក៏សំខាន់ដូចជាសេចក្តីបង្រៀនរបស់គាត់ផងដែរ។

ដូច្នេះ នៅក្នុងខ.២២-២៥ សាវកប៉ុលនិយាយអំពីអនាគតគាត់ ហើយអ្វីដែលគាត់ជ្រើសរើសនិយាយគឺជាការជំរុញចិត្តដ៏ខ្លាំងដល់ពួកចាស់ទុំក្នុងពួកជំនុំ។ ក្នុងនាមជាចាស់ទុំម្នាក់នៅក្នុងពួកជំនុំនេះ ខ្ញុំអាចនិយាយថាទីបន្ទាល់របស់សាវកប៉ុលនេះធ្វើអោយខ្ញុំចង់លក់ទ្រព្យសម្បត្តិទាំងអស់របស់ខ្ញុំ ហើយដើរតាមព្រះយេស៊ូវ។ គ្រប់ពេលខ្ញុំត្រឡប់មកឯពាក្យសំដីសំខាន់ៗរបស់សាវកប៉ុល វាធ្វើអោយខ្ញុំចង់បោះបង់ចោលគ្រប់យ៉ាង ដើម្បីអោយខ្ញុំអាចដើរតាមនិងបំរើព្រះគ្រីស្ទដោយស្មោះត្រង់!

ខ្ញុំបានព្យាយាមសង្ខេបព្រះរាជសារនៅក្នុងខទាំងបួនដោយពាក្យថា សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត។ ខ្ញុំសង្ឃឹមថា អ្នកនឹងយល់ស្របថា នេះគឺជាការសង្ខេបត្រឹមត្រូវនៃខ.២៤ ដែលនិយាយថា «ប៉ុន្តែ នោះមិនអំពល់អ្វីដល់ខ្ញុំទេ ខ្ញុំក៏មិនរាប់ជីវិតនេះ ទុកជារបស់វិសេសដល់ខ្ញុំដែរ ឲ្យតែខ្ញុំបានបង្ហើយការរត់ប្រណាំងរបស់ខ្ញុំដោយអំណរចុះ ព្រមទាំងការងារ ដែលខ្ញុំបានទទួលអំពីព្រះអម្ចាស់យេស៊ូវ...»។ សេចក្តីស្មោះត្រង់ចំពោះការត្រាស់ហៅរបស់ខ្ញុំសំខាន់ខ្លាំងជាងជីវិតរបស់ខ្ញុំទៅទៀត!

**សំនួរពីរអំពីសាររបស់សាវកប៉ុល**

ដូច្នេះ ខ្ញុំចង់ឆ្លើយនឹងសំនួរពីរនេះដោយប្រើខទាំងនេះជាមូលដ្ឋានគ្រឹះសំរាប់ចម្លើយ៖

១. តើពាក្យថា សេចក្តីស្មោះត្រង់ប្រសើរជាងជីវិតមានន័យយ៉ាងដូចម្តេច?

២. ហេតុអ្វីសេចក្តីស្មោះត្រង់ប្រសើរជាងជីវិត?

នៅក្នុងខទាំងនេះគឺជាសាររបស់សាវកប៉ុលទៅកាន់ពួកចាស់ទុំក្នុងពួកជំនុំក្រុងអេភេសូរនិងមកកាន់យើងនៅសព្វថ្ងៃនេះផងដែរ សារនោះគឺថា៖ សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត។ គ្រីស្ទបរិស័ទគ្រប់គ្នា (ជាពិសេស

ពួកចាស់ទុំ) គួរតែចាត់ទុកសេចក្តីស្មោះត្រង់ចំពោះការត្រាស់ហៅរបស់ព្រះគ្រីស្ទប្រសើរជាងសេចក្តីសុខសាន្ត ក្នុងជីវិត ហើយប្រសើរជាងការមានជីវិតនៅរស់ផងដែរ។

### ១. តើវាមានន័យយ៉ាងដូចម្តេច?

តើពាក្យថា សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត មានន័យដូចម្តេច?

### ១.១. ត្រូវព្រះវិញ្ញាណទាក់ទាញអោយតាមបំណងព្រះហឫទ័យរបស់ព្រះ

ខ.២២ «ឥឡូវនេះ ព្រះវិញ្ញាណបានទាក់ទាញចិត្តខ្ញុំអោយធ្វើដំណើរទៅក្រុងយេរូសាឡឹម » តើពាក្យ «ព្រះវិញ្ញាណបានទាក់ទាញចិត្តខ្ញុំ» មានន័យយ៉ាងម៉េច?

យើងមិនអាចដឹងជឿជាក់ថា ពាក្យ «វិញ្ញាណ» នេះជាវិញ្ញាណរបស់សាវកប៉ុល (ដូចក្នុងព្រះគម្ពីរភាសាខ្មែរបកប្រែចាស់) ឬជាវិញ្ញាណរបស់ព្រះ (ដូចក្នុងព្រះគម្ពីរភាសាខ្មែរបកប្រែថ្មី) ទេ។ អ្នកត្រូវតែសំរេចចិត្តដោយផ្អែកលើបរិបទ។ ខ្ញុំគិតថា ពាក្យនេះសំដៅទៅលើវិញ្ញាណរបស់ព្រះ។

ប៉ុន្តែ ការបកប្រែទាំងពីរនេះមិនសូវខុសគ្នាទេ ពីព្រោះបើសិនអ្នកសួរថា តើអ្នកណាទាក់ទាញវិញ្ញាណរបស់សាវកប៉ុល? ឬតើអ្នកណាកំពុងបង្គាប់គាត់នៅក្នុងផ្លូវនេះ? នោះចំលើយពិតជា វិញ្ញាណរបស់ព្រះ។ ដូច្នេះសាវកប៉ុលគឺជាមនុស្សម្នាក់នៅក្រោមចិត្តជឿជាក់និងការបង្គាប់ គឺវិញ្ញាណរបស់គាត់ត្រូវទាក់ទាញជាប់ដោយវិញ្ញាណរបស់ព្រះអោយធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះ។

ដូច្នេះហើយ នេះគឺជាចំណុចដំបូង៖ ការជឿថា សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត មានន័យថា ព្រះវិញ្ញាណទាក់ទាញយើងអោយធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះ។ វិញ្ញាណរបស់ព្រះចាប់ជាប់វិញ្ញាណរបស់អ្នក ហើយគ្រប់គ្រងលើអ្នក ដូច្នេះបំណងព្រះហឫទ័យរបស់ព្រះគឺជាភាពឆេះឆួលរបស់អ្នក។

### ១.២. ស្កប់ចិត្តក្នុងការមិនដឹងលំអិតពីអនាគត

ទីពីរ សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត មានន័យថា អ្នកស្កប់ចិត្តដែលមិនដឹងសេចក្តីលំអិតអំពីអ្វី ដែលនឹងកើតឡើង។

ខ.២២ «ឥឡូវនេះ ព្រះវិញ្ញាណបានទាក់ទាញចិត្តខ្ញុំអោយធ្វើដំណើរទៅក្រុងយេរូសាឡឹម ហើយខ្ញុំមិនដឹងថានឹងមានហេតុការណ៍អ្វីកើតមានដល់ខ្ញុំ នៅក្រុងនោះឡើយ...»។ មូលហេតុដែលសាវកប៉ុលនិយាយសេចក្តីនេះគឺដើម្បីបង្ហាញយើងថា បើ «សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត» នោះអ្នកមិនចាំបាច់ដឹងអំពីសេចក្តីលំអិតពីអនាគតឡើយ។

នេះគឺជាការដោះលែងអោយមានសេរីភាពយ៉ាងខ្លាំង ។ បើសិនអ្នកជាមនុស្សទុទ្ទិដ្ឋិនិយមម្នាក់ នោះអ្នកប្រហែលជាគិតអំពីរឿងអាក្រក់ជាច្រើន ដែលអាចមានកើតឡើងនៅអនាគត ហើយគំនិតទាំងនោះធ្វើអោយអ្នកមានកង្វល់ និងសេចក្តីវេទនា។ «ខ្ញុំប្រហែលជាមិនអាចឃាត់ប្តីប្រពន្ធរបស់ខ្ញុំមិនអោយចាកចេញទៅបានទេ។ ខ្ញុំប្រហែលជាមិនអាចជួយកូនរបស់ខ្ញុំអោយចេញពីបញ្ហាបានទេ។ ខ្ញុំប្រហែលជាមិនអាចរក្សាការងាររបស់ខ្ញុំបានទេ។ ខ្ញុំប្រហែលជាមិនអាចនាំឪពុករបស់ខ្ញុំអោយជឿព្រះគ្រីស្ទបានទេ។» ប៉ុន្តែអត្ថបទនេះមានន័យថា អ្នកមិនចាំបាច់ត្រូវដោះស្រាយបញ្ហាទាំងអស់ដែលនឹងកើតឡើងនៅអនាគតទេ ប៉ុន្តែអ្វីដែលព្រះតម្រូវអោយអ្នកធ្វើនៅអនាគតគឺថា អ្នកស្មោះត្រង់ចំពោះទ្រង់។ នេះគឺជាការដោះលែងខ្លួនយ៉ាងខ្លាំង ហើយវានាំយើងទៅដល់ចំនុចទីបី៖

## ១.៣. មិនបោះបង់ព្រះគ្រីស្ទចោលនៅក្នុងសេចក្តីវេទនា

សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត មានន័យថា អ្នកមិនបោះបង់ព្រះគ្រីស្ទចោល នៅពេលភាពស្មោះត្រង់របស់យើងនាំអោយយើងមានសេចក្តីវេទនាឡើយ។

នៅក្នុងខ.២៣ សាវកប៉ុលនិយាយថា មានសេចក្តីមួយ ដែលគាត់ដឹងអំពីអនាគតគឺ «...ព្រះវិញ្ញាណបរិសុទ្ធធ្វើបន្ទាល់ដល់ខ្ញុំ នៅគ្រប់ទីក្រុងថា មានចំណង និងសេចក្តីវេទនា នៅរង់ចាំខ្ញុំ»។

បើសិនអ្នកអាចនិយាយដោយស្មោះត្រង់ជាមួយសាវកប៉ុលថា «សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត» នោះមានន័យថា អ្នកអាចស្កប់ចិត្តចំពោះការដឹងប្រាកដជាក់ថា ក្នុងពេលអនាគតនឹងមានការឈឺចាប់ដោយសារយើងតាមព្រះគ្រីស្ទ។ ព្រះវិញ្ញាណបរិសុទ្ធប្រាប់សាវកប៉ុលថា មានចំណងនិងសេចក្តីវេទនានៅរង់ចាំគាត់នៅក្នុងទីក្រុងទាំងអស់។

ហេតុអ្វីសាវកប៉ុលប្រាប់ពួកចាស់ទុំពួកជំនុំអេភេសូរទាំងអស់អំពីសេចក្តីនេះ? ដើម្បីបង្រៀនពួកគេថា រឿងអាក្រក់ទាំងអស់នោះមិនមែនជាបញ្ហាទេ។ ទោះជាយ៉ាងណាក៏ដោយ គាត់នឹងឆ្ពោះទៅមុខ។ ហើយនេះជាអ្វីដែលពួកចាស់ទុំក្នុងពួកជំនុំរបស់យើងគួរតែធ្វើផងដែរ។ នឹងមានទុក្ខលំបាក ការឈឺចាប់ បញ្ហា និងសេចក្តីវេទនា។ សាវកប៉ុលបាននិយាយទៅកាន់ពួកជំនុំទាំងអស់នៅក្នុងកិច្ចការ ១៤:២២ថា «ត្រូវតែទ្រាំរងទុក្ខវេទនាជាច្រើន ទើបនឹងចូលទៅក្នុងនគរព្រះបាន» (សូមមើល២ធីម៉ូថេ ៣:៣-១២ ផងដែរ)។ ទុក្ខវេទនាទាំងនេះនឹងល្បងលយើងអោយដឹងថា យើងជឿថាសេចក្តីស្មោះត្រង់ប្រសើរជាងជីវិតឬយ៉ាងណា។

## ១.៤. មានសេចក្តីប្រាថ្នាផ្ទុយនឹងសេចក្តីប្រាថ្នានៃវប្បធម៌របស់យើង

ដូច្នេះ ចំលើយចុងក្រោយនៅក្នុងខនេះចំពោះសំនួរដែលថា តើពាក្យថា សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត មានន័យយ៉ាងដូចម្តេច? គឺដូច្នេះ៖ វាមានន័យថា អ្នកទាស់ប្រឆាំងនឹងសេចក្តីប្រាថ្នានៃវប្បធម៌របស់មនុស្ស (ទោះជាវប្បធម៌អាមេរិក ឬវប្បធម៌ខ្មែរ)។

ខ.២២ «ឥឡូវនេះ មើល ខ្ញុំមានសេចក្តីបណ្តាលក្នុងចិត្តចង់ទៅឯក្រុងយេរូសាឡិម»។ មិនថាមានរឿងអ្វីកើតឡើងឡើយ! មិនខ្វល់ថាមានឥទ្ធិពលអ្វីមកលើសុវត្ថិភាពរបស់ខ្ញុំនិងជីវភាពរស់នៅឡើយ។

សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត! ប្រសើរជាងជីវិតទំនេរនៅក្នុងការចូលនិវត្តន៍ ប្រសើរជាជីវិតទំនេរនៅក្នុងវ័យកណ្តាល ហើយប្រសើរជាងជីវិតទំនេរនៅក្នុងយុវវ័យផងដែរ។ ហេតុអ្វី?

## ២. ហេតុអ្វីវាប្រសើរជាងជីវិត?

ហេតុអ្វីសេចក្តីស្មោះត្រង់ប្រសើរជាងជីវិត? នេះគឺជាសំនួរទីពីររបស់យើង។

យ៉ាងហោចណាស់មានចំលើយពីរនៅក្នុងខ.២៤និង២៥។

### ២.១. ការបង្ហើយការរត់ប្រណាំង

ទីមួយ «សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត» ពីព្រោះសេចក្តីស្មោះត្រង់មានន័យថាជា ការរត់ប្រណាំងដល់ទីដៅ ហើយអ្នករត់ប្រណាំងដល់ទីដៅនោះនឹងទទួលបានមកុដ។

សាវកប៉ុលនិយាយនៅក្នុងខ.២៤ថា «ខ្ញុំក៏មិនរាប់ជីវិតនេះ ទុកជារបស់វិសេសដល់ខ្ញុំដែរ តែខ្ញុំបានបង្ហើយការរត់ប្រណាំងរបស់ខ្ញុំ»។ សាវកប៉ុលចង់បង្ហើយការរត់ប្រណាំងរបស់គាត់ដោយមិនគេចពីការតប់ប្រមល់ ឬការខកចិត្ត ឬការឈឺចាប់។

មានកន្លែងមួយទៀតនៅក្នុងព្រះគម្ពីរ ដែលពាក្យនេះ គឺនៅក្នុងសំបុត្រទីពីររបស់សាវកប៉ុលទៅកាន់ធីម៉ូថេ (៤:៧-៨)។ នៅចុងបញ្ចប់នៃជីវិតរបស់គាត់ ប្រហែលជាប្រាំមួយ ឬប្រាំបីឆ្នាំបន្ទាប់ពីការជួបជាមួយពួកចាស់ទុំពួកជំនុំអេភេសូរ គាត់សរសេរថា «ខ្ញុំបានតយុទ្ធយ៉ាងល្អ ខ្ញុំបានរត់ប្រណាំងជាស្រេច [ឃ្លាដូចគ្នា] ខ្ញុំបានរក្សាសេចក្តីជំនឿទៅហើយ ពីនេះទៅមុខ នឹងមានមកុដនៃសេចក្តីសុចរិត បំរុងទុកឲ្យខ្ញុំ ដែលព្រះអម្ចាស់ដ៏ជាចៅក្រមសុចរិត ទ្រង់នឹងប្រទានមកខ្ញុំនៅថ្ងៃនោះ មិនមែនដល់ខ្ញុំតែម្នាក់ប៉ុណ្ណោះ គឺដល់អស់អ្នកណាដែលចូលចិត្តនឹងដំណើរទ្រង់យាងមកវិញនោះដែរ»។

និយាយតាមពាក្យផ្សេង សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត ពីព្រោះលើសពីជីវិតដ៏ខ្លីនេះ យើងមានជីវិតពេញដោយអំណរដ៏អស្ចារ្យ ដែលនឹងស្ថិតស្ថេរអស់កល្បជានិច្ច ហើយអស់អ្នកណា ដែលស្មោះត្រង់នៅទីនេះ នឹងចូលទៅក្នុងជីវិតនោះ ហើយទទួលបានមកុដនៃសេចក្តីសុចរិតមួយ។

អត្ថបទដែលទាក់ទងនឹងផ្ទៃរឿងនេះមានរួមទាំង៖

«តែអ្នកណាដែលកាន់ខ្ជាប់ ដរាបដល់ចុងបំផុតវិញ អ្នកនោះនឹងបានសង្គ្រោះ» (ម៉ាថាយ ២៤:១៣)

«ដ្បិតសេចក្តីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឱ្យយើងខ្ញុំមានសិរីល្អ យ៉ាងធ្ងន់លើសលប់ ដ៏នៅអស់កល្បជានិច្ចវិញ» (២កូរិនថូស ៤:១៧)

«អ្នករាល់គ្នាមានពរក្នុងកាលដែលគេជេរ បៀតបៀន ហើយនិយាយបង្ខុសគ្រប់ ទាំងសេចក្តីអាក្រក់ពីអ្នករាល់គ្នាដោយព្រោះខ្ញុំចូរមានចិត្តអំណរ ហើយរីករាយជាខ្លាំងចុះ ដ្បិតអ្នករាល់គ្នាមានរង្វាន់ជាធំនៅ ឯស្ថានសួគ៌ ពីព្រោះគេក៏បានធ្វើទុក្ខដល់ពួកហោរា ដែលនៅមុនអ្នករាល់គ្នាបែបដូច្នោះដែរ។» (ម៉ាថាយ ៥:១១-១២)

«ឯអស់អ្នកណាដែល លះចោលផ្ទះសំបែង ឬបងប្អូនប្រុសស្រី ឪពុកម្តាយ ប្រពន្ធ កូន ឬស្រែចំការ ដោយយល់ដល់ឈ្មោះខ្ញុំ១ នោះនឹងបានជា ១រយភាគឡើងវិញ ហើយនិងបានគ្រងជីវិតអស់កល្បជានិច្ច ទុកជាមរដកដែរ» (ម៉ាថាយ ១៩:២៩)

«អ្នកណាដែលស្រឡាញ់ជីវិតខ្លួន នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលស្អប់ជីវិតខ្លួននៅ លោកិយនេះវិញ នោះនឹងរក្សាជីវិតទុក ដរាបដល់អស់កល្បរៀងទៅ» (យ៉ូហាន ១២:២៥)

«ចូរឱ្យចូលតាមទ្វារចង្អៀត ដ្បិតទ្វារដែលនាំទៅឯ សេចក្តីហិនវិនាសនោះធំ ហើយទូលាយផង ក៏មានមនុស្សជាច្រើនដែល ចូលតាមទ្វារនោះតែឯទ្វារដែលនាំទៅឯជីវិតនោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ ដែលរកផ្លូវនោះឃើញ។» (ម៉ាថាយ ៧:១៣-១៤)

ហេតុអ្វីសេចក្តីស្មោះត្រង់ប្រសើរជាងជីវិត? ពីព្រោះសេចក្តីស្មោះត្រង់គឺជាការរត់ប្រណាំងជាស្រេច ហើយការរត់ប្រណាំងជាស្រេចនាំយើងទៅកន្លែងដែលយើងមានអំណរជារៀងរហូត។

នេះនាំអោយមានសំនួរចុងក្រោយគឺ តើអ្វីជាមូលដ្ឋានគ្រឹះនៃទំនុកចិត្តរបស់សាវកប៉ុលថា «ប្រកាសប្រាប់ពីនគរនៃព្រះ»? ហើយតើអ្វីជាមូលដ្ឋានគ្រឹះសំរាប់ទំនុកចិត្តរបស់គាត់ និងទំនុកចិត្តរបស់យើងថា សេចក្តីស្មោះត្រង់ចំពោះព្រះ  នឹងនាំអោយយើងទទួលសេរីរុងរឿងក្នុងពេលអនាគត?

## ២.២. ព្រះពេញដោយព្រះគុណ ហើយព្រះគឺជាស្តេច

ចំលើយមាននៅក្នុងឃ្លាពីរ៖ មួយនៅចុងបញ្ចប់នៃខ.២៤ ហើយមួយទៀតនៅជិតចុងបញ្ចប់នៃខ. ២៥។ ឃ្លាទីមួយគឺ «ដំណឹងល្អនៃព្រះគុណព្រះ»។ កិច្ចការដែលសាវកប៉ុលចង់សំរេចគឺជាកិច្ចការ ដែលគាត់បានទទួលមកពីព្រះអម្ចាស់យេស៊ូវ គឺ «ធ្វើបន្ទាល់សព្វគ្រប់ ពីដំណឹងល្អនៃព្រះគុណព្រះ»។

ឃ្លាទីពីរគឺ «ការប្រកាសប្រាប់ពីនគរ» នៅក្នុង៦.២៥។ «ឥឡូវនេះ មើល ខ្ញុំដឹងហើយថា ក្នុងពួកអ្នករាល់គ្នាដែលខ្ញុំបានដើរទៅមកជាមួយ ដោយភប់ប្រសព្វគ្នា ទាំងប្រកាសប្រាប់ពីនគរនៃព្រះ នោះគ្មានអ្នកណាមួយនឹងឃើញមុខខ្ញុំទៀតឡើយ»។

ដូច្នេះ ដោយពីរឃ្លាសាវកប៉ុលបានសង្ខេបខ្លឹមសារនៃការងារក្នុងជីវិតរបស់គាត់។ ទីមួយ «ធ្វើបន្ទាល់សព្វគ្រប់ពីដំណឹងល្អនៃព្រះគុណព្រះ» ហើយទីពីរ «ប្រកាសប្រាប់ពីនគរនៃព្រះ»។ គាត់បានរស់នៅ ដើម្បីប្រកាសអោយមនុស្សបានដឹងអំពីព្រះគុណព្រះ  និងនគរព្រះ។

ដូច្នេះ នេះគឺជាចំលើយទៅនឹងសំនួររបស់យើង៖ មូលដ្ឋានគ្រឹះនៃជីវិតនិងសេចក្តីសង្ឃឹមរបស់គាត់គឺថា ព្រះពេញដោយព្រះគុណ ហើយថា ព្រះគឺជាស្តេច។ ហើយនេះគឺជាមូលដ្ឋានគ្រឹះនៃទំនុកចិត្តរបស់យើងថា សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត៖ បើសិនព្រះគឺជាស្តេច នោះទ្រង់*អាច*ប្រទានរង្វាន់ដល់អ្នកស្មោះត្រង់ ហើយគ្មានអ្វីអាចបញ្ឈប់អំណាចរបស់ទ្រង់បានឡើយ។ បើសិនព្រះពេញដោយព្រះគុណ នោះទ្រង់*នឹង*ប្រទានរង្វាន់ដល់អ្នកស្មោះត្រង់។

ដូច្នេះ ព្រះរាជសារនេះនៅតែរឹងមាំនៅសព្វថ្ងៃនេះ គឺរឹងមាំ និងពិតប្រាកដដូចជាអធិបតីភាព និងព្រះគុណរបស់ព្រះនៅក្នុងព្រះយេស៊ូវគ្រីស្ទ៖ សេចក្តីស្មោះត្រង់ប្រសើរជាងជីវិត។ ដូច្នេះ ខ្ញុំលើកទឹកចិត្តអ្នកថា ចូរកុំអោយពាក្យសំដីរបស់លោកិយជាអ្នកកំណត់  តែទុកអោយព្រះបន្ទូលរបស់ព្រះកំណត់អ្វី ដែលប្រសើរជាងជីវិតអ្នកចុះ។